# អភិបាលកិច្ចតាមបែប ពីក្រោមទៅលើ

## យុទ្ធសាស្រ្តអភិវឌ្ឍន៍

**SOS2-ASOG**

*ភ្នំពេញ ប្រទេសកម្ពុជា ថ្ងៃទី១៧-១៨ ខែវិច្ឆិកា ឆ្នាំ២០០៨*

*ដោយ :**Mayor Sonia R. Lorenzo***

សាលាក្រុង San Isidro បានចាប់ផ្តើមឡើងដោយមានជំនឿជារួមថា ការអភិវឌ្ឍជីវភាពរស់នៅរបស់គ្រួសារ និងការស្តារសហគមន៍ឡើងវិញ គឺត្រូវមានការពឹងផ្អែកលើគ្នាទៅវិញទៅមក និងមានកម្លាំងរួបរួមគ្នា។ ចំពោះគ្រួសារ ដែលរស់នៅតាមទីជនបទ ទោះបីជាពួកគាត់មានជីវភាពក្រីក្រយ៉ាងណាក៏ដោយ ប្រសិនបើមានការផ្តល់ឱកាស និង ផ្តល់ជំនួយសមស្របដល់ពួកគេ វាអាចធ្វើឱ្យជីវិតរស់នៅ របស់ពួកគាត់មានភាពប្រសើរឡើង។ វាអាចធ្វើទៅបាន លុះណាតែប្រជាជនខ្លួនឯងយល់ពីគោលការណ៍នៃការតស៊ូមតិ ដើម្បីធ្វើការអភិវឌ្ឍជនបទ ដែលអាចសំរេចបានដោយ ចំណាយពេលយូរ។

San Isidro ជាស្រុកទី៤ នៃខេត្ត Nueva Ecija ដែលមានផ្ទៃដីសរុប ៧ ៧៤០ ហិកតា និងមានចំនួនប្រជាជន ៤៤,៦៨៧ នាក់។ អ្នកដែលរស់នៅទីនេះភាគច្រើនពឹងផ្អែកទៅលើរបរកសិកម្ម ដែលចាត់ទុកថា ជារដ្ឋក្រីក្រមួយ។ ទោះជាយ៉ាងណាក៏ដោយ យើងនៅតែអាចសម្រេចបាននូវគោលដៅរបស់យើង តាមរយៈបណ្តារកម្មវិធីដែលឆ្លើយតប ទៅនឹងតំរូវការរបស់ប្រជាពលរដ្ឋ និងបានផ្តល់អំណាចដល់ពលរដ្ឋ ដើម្បីធ្វើអោយសមភាពនៅក្នុងសង្គម។

## ស្លាយ : ចក្ខុវិស័យ/បេសកកម្ម

យើងបានចាប់ផ្តើមជាមួយនឹងចក្ខុវិស័យរួមគ្នាស្តីពី “ធ្វើអោយប្រសើរឡើងនូវគុណភាពរស់នៅរបស់ប្រជាជន San Isidro និងបេសកកម្មរួមគ្នា” ដើម្បីអនុវត្ត និងធ្វើឱ្យមាននិរន្តរភាពនូវការអភិវឌ្ឍសេដ្ឋកិច្ចសង្គមតាមរយៈកម្មវិធីពួតដៃគ្នា និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងអភិបាលកិច្ចរបស់ San Isidro។

## ស្លាយ : យុទ្ធសាស្រ្ត

**១.** <u>**ការរៀបចំឡើងវិញ**</u>- យើងអាចសន្សំបាន ៣ ២៦៨M ក្នុងមួយឆ្នាំ ដែលត្រូវបានប្រើជាមូលនិធិសំរាប់កម្មវិធីសេវាសង្គមនានា។ នៅពេលជាមួយគ្នានោះដែរ នៅក្នុងការបង្កើតការិយាធិបតេយ្យជំនាញ

របស់យើង យើងអាចមានលទ្ធភាពបង្កើតផែនការអភិវឌ្ឍន៍រយៈមធ្យមមួយ ដែលបង្រៀនគ្រួសារ និងសហគមន៍ឱ្យគ្រប់គ្រង កម្មវិធី និងសកម្មភាពនៅក្នុងតំបន់របស់ពួកគេ ដោយគិតគូពីអនាគតរបស់កុមារ ។

បញ្ហាដែលគ្រួសារជាកសិករ និងគ្រួសារមិនមែនជាកសិករជួបប្រទះ គឺមានទំនាក់ទំនង និងមានភាពចាក់ស្រេះគ្នា។ ដូច្នេះ កម្មវិធីអភិវឌ្ឍត្រូវតែធ្វើឡើងរួមគ្នា និងសហការណ៍គ្នា ដើម្បីដោះស្រាយ បញ្ហានៅក្នុងគ្រប់ទិដ្ឋភាព នៃជីវិតរបស់ប្រជាជន ។

កម្មវិធីប្រយុទ្ធនឹងភាពក្រីក្ររបស់ San Isidro (SIAAP) បានបង្កើតឡើងស្របទៅនឹងច្បាប់ សាធារណរដ្ឋលេខ៨៤២៥ និងមានទិសដៅជាយុទ្ធសាស្រ្តមួយ ព្រមទាំងមានមូលដ្ឋាន ដើម្បីធ្វើដំណើរឆ្ពោះ ទៅមុខជានិច្ច។ គោលបំណងរបស់យើង គឺធ្វើអោយប្រសើរឡើងនូវគុណភាពជីវិតរស់នៅ តាមរយៈការ ផ្តល់សេវាកម្មជាមូលដ្ឋាន និងឱកាសការងារដែលបានមកពីវិស័យកសិកម្ម ពាណិជ្ជកម្ម និងឧស្សាហ៍កម្ម ។

ផ្នែកគ្រប់គ្រងគម្រោងមានអ្នកតំណាងមកពីក្រុមពហុវិស័យ និងភ្នាក់ងាររដ្ឋាភិបាលដែលបានដោះស្រាយបញ្ហាយ៉ាងប៉ិនប្រសព្វ ដែលនឹងឈានទៅបង្កើនទិន្នផលរបស់កសិករ ។

## ២. <u>ការបញ្ចូលគ្នារវាងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច</u>

ទស្សនៈស្តីពីគម្រោងប្រព័ន្ធកសិកម្មចំរុះពួតដៃគ្នា គឺជាវិធីសាស្រ្តធ្វើស្រែចំការរួមគ្នាមួយ ដែលបែងចែកដោយ ប្រតិបត្តិការកិសកម្មចំរុះ ការត្រៀមផលិត ដំណើរការផលិត និងការអនុវត្តទីផ្សារ ជាឯកពាណិជ្ជកម្មស្ថិតនៅក្រោម ការគ្រប់គ្រងតែមួយ ។

ទស្សនៈនេះបានរៀបចំចប់សព្វគ្រប់ទៅតាមលំដាប់លំដោយនៃការប្រឹក្សាយោបល់ជាមួយនឹង កសិករ បណ្តារ អ្នកដឹកនាំសហគមន៍ និងសង្គមស៊ីវិល ។

**៣. ការបង្កើត CCSI** –ការអនុវត្តកម្មវិធីប្រកបដោយប្រសិទ្ធភាព គឺជាការចាំបាច់ ដើម្បីសម្រេចបាននូវ គោលដៅនានារបស់យើង។ ការរួបរួមគ្នាយ៉ាងខ្លាំងខ្លារបស់ San Isidro, ការរួបរួមគ្នាជាបក្សនៃអ្នកដឹកនាំពហុវិស័យ គឺត្រូវបានបង្កើតឡើងដើម្បីរៀបចំគំរោងកម្មវិធីទៅដល់ថ្នាក់មូលដ្ឋាន ដោយដាក់អោយដំណើរការនៅតំបន់ណា ដែល បណ្តារអ្នកពាក់ព័ន្ធនឹងមានបញ្ហាផ្ទាល់ខ្លួនដូចគ្នា ហើយចូលរួមបង្កើតការរៀបចំថ្មីមួយ ដែលនឹងនាំអោយប្រជាពលរដ្ឋ ទទួលបាននូវអំណាច និងក្លាយជាស្ថាបនមួយដែលឆ្លើយតបទៅនឹងតំរូវការពលរដ្ឋ។ ដំណើរការនេះធ្វើឡើងតាមរយៈការសន្ទនាគ្នាជាបន្តបន្ទាប់ដើម្បីកសាងទំនុកចិត្ត រហូតទាល់តែសម្រេចបាននូវការឆ្លើយតបជារួមមួយ ហើយការ

រៀបចំថ្មីមួយត្រូវបានបង្កើតឡើង។ សកម្មភាពទាំងនេះបានធ្វើឱ្យយើងមានលទ្ធភាព គូផែនទីផ្លូវនៃតំបន់គោលដៅរបស់យើង VMOKRAPI ។

**៤.** **<u>ដោយសារតែគម្រោងថវិកា</u>**-ក្រុងរបស់យើងមានកំណត់ ដូច្នេះយើងមិនមាន សេរីភាពក្នុងការអនុវត្ត គម្រោងសេវាសង្គមដែលចាំបាច់ទាំងអស់ ដើម្បីសម្រេចគោលដៅរបស់យើងបានទេ។ យើងបានផ្តល់អាទិភាពទៅលើ ផ្នែកសុខាភិបាល ដោយសារតែបញ្ហាស្ទើរតែទាំងអស់នៅតាម មូលដ្ឋានគឺពាក់ព័ន្ធទៅនឹងសុខភាព។

យើងបានបែងចែកថវិការបស់ក្រុង ១៦.៥% ទៅឱ្យវិស័យសុខាភិបាល ដើម្បីរក្សានិរន្តរភាពប្រព័ន្ធថែរក្សា សុខភាពមូលដ្ឋាន BARANGAY និងថែរក្សាគ្លីនិកប្រមូលផ្តុំអ្នកជំងឺ CLIENT CENTERED CLINIC។ ថវិកា ៣៥.៥៦% បានមកពីការរួមចំណែកដោយស្ម័គ្រចិត្តចំនួន P ២០០/ឆ្នាំ/គ្រួសារ និងពន្ធអាករពីរដ្ឋាភិបាលថ្នាក់ជាតិ ហើយ ៦៤.៤៤% ទៀតបានមកពីថវិការបស់សាលាក្រុង។

ដើម្បីកាត់បន្ថយភាពក្រីក្រ និងសម្រេចឱ្យបាននូវសមូហភាពសង្គម យើងជឿជាក់ថា ការផ្តល់សេវាធានារ៉ាប់រងសុខភាព ត្រូវតែពង្រីកទៅដល់ប្រជាជនដែលមិនបានទទួលការគាំពារផ្នែកសន្តិសុខសង្គមជាផ្លូវការ។ យើង មានលទ្ធភាពចុះឈ្មោះគ្រួសារចំនួន ៩.៥៤១គ្រួសារ ដោយលៃលកប្រាក់បម្រុង ទុកសម្រាប់ការទូទាត់បន្ថែមពីលើ PHILHEALTH sa MASA។ កម្មវិធីនេះអនុវត្តដោយ ស្ត្រីដែលទទួលបានការបណ្តុះបណ្តាលចំនួន ១០៨ នាក់ មកពីថ្នាក់មូលដ្ឋាន ហៅថាបុគ្គលិកសុខភាព Barangay ឬ BHW ដែលត្រូវទទួលបន្ទុកគ្រួសារពី ៥០ ទៅ ១០០ គ្រួសារ។ កម្មវិធីសុខភាពរបស់យើង បានធ្វើស្ថាបនូបនីយកម្មតាមរយៈដំណោះស្រាយរបស់ក្រុមប្រឹក្សាក្រុង។

**៥.** **<u>ការគៀងគររបស់ស្ថាប័ន</u>**

ជាមួយនឹងកម្មវិធីសុខភាពនៅនឹងកន្លែងរបស់យើង យើងអាចទាក់ទងជាមួយដៃគូនានាឱ្យជួយយើងនៅក្នុង កម្មវិធីផ្សេងៗទៀត ដោយប្រើរបៀបវារៈសុខាភិបាលរបស់ San Isidros ធ្វើជាគ្រឹះរបស់យើង។

នៅក្នុងវិស័យអប់រំ មណ្ឌលអភិវឌ្ឍន៍ការអប់រំ Ateneo បានបង្រៀនយើងពីសារៈសំខាន់នៃការរៀបចំគម្រោងសាលា ដើម្បីសម្រេចគោលដៅរបស់យើង។ ពីឆ្នាំ១៩៩៧-១៩៧៥ ចលនាកែប្រែការអប់រំរបស់មូលនិធិសមាគមដែលធ្វើការរួមគ្នា
បានផ្តល់ឱ្យយើងនូវយុត្តាធិការដើម្បីចាប់ដៃគូជាមួយស្ថាប័នក្នុងតំបន់របស់យើង

ក្នុងការលើកឡើងនូវកង្វល់ផ្សេងៗនៅក្នុងវិស័យអប់រំ ដោយមិនគ្រាន់តែនៅក្នុងសហគមន៍របស់យើងប៉ុណ្ណោះទេ តែថែមទាំងនៅក្នុងខេត្តទាំងមូលទៀតផង។

យើងមានលទ្ធភាពផ្តល់របរចិញ្ចឹមជីវិត ដោយប្រែក្លាយតំបន់សម្រាប់ពិសោធន៍មួយ គឺមជ្ឈមណ្ឌលបណ្តុះបណ្តាលកសិកម្ម ភីលីពីន-អ៊ីស្រាអែល ដែលជាគម្រោងគ្រប់គ្រងដោយរដ្ឋាភិបាលភីលីពីន និងរដ្ឋអ៊ីស្រាអែល។ យើងបានរៀបចំវគ្គបណ្តុះបណ្តាលជំនាញជាមួយនឹងឱកាសផលិតកម្ម ដោយធ្វើជាដៃគូជាមួយភ្នាក់ងារជាតិ និងសង្គម ស៊ីវិល។

នៅ San Isidro កសិករគឺជាក្រុមមនុស្សភាគច្រើនមួយ។ ចំនួនប្រជាជនពី ៧៥% ទៅ៨0% ពឹងផ្អែកលើ
វិស័យកសិកម្មដើម្បីទ្រទ្រង់ជីវភាពរស់នៅហើយមនុស្សភាគច្រើនស្ថិតនៅក្នុងក្រុមមនុស្សដែលមានប្រាក់ចំណូលទាប។ កម្មវិធីលំនៅដ្ឋានរបស់រដ្ឋាភិបាលដែលមានស្រាប់ អាចបំពេញតាមតម្រូវការដល់ផ្នែកផ្សេងៗគ្នានៃសង្គមរបស់យើង ប៉ុន្តែមិនបានដល់កសិករនោះទេ ត្រូវដឹងថាកសិករដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្គត់ផ្គង់អាហារដល់ជាតិទាំងមូល។
វាជាការសមស្របដែលកសិករត្រូវបានផ្តល់ឱកាស ដើម្បីសង់ផ្ទះស្នាក់នៅអោយបានសមរម្យនោះ។ តាមរចាប់ដៃគូជាមួយភ្នាក់ងាររដ្ឋាភិបាល PAG-IBIG ដែលបានធ្វើឱ្យយើងមានលទ្ធភាពបង្កើតកម្មវិធីថ្មី មួយដែលបើកចំហសម្រាប់កសិករដើម្បីទទួលបានមូលនិធិសម្រាប់សាងសង់លំនៅដ្ឋាន។

ភាពជាដៃគូរបស់យើងជាមួយ GAWAD KALINGA នៅក្នុងការផ្តល់ផ្ទះសម្រាប់អ្នកដែលគ្មានផ្ទះសម្បែង និងដីសម្រាប់អ្នកដែលគ្មានដីធ្លី គឺកំពុងព្យាយាមដោះស្រាយបញ្ហារបស់យើជាមួយនឹងអ្នក ដែលរស់នៅក្នុងអាគារដែលគេបោះបង់ចោល និងគ្រួសារដែលរងផលប៉ះពាល់ពីគ្រោះមហន្តរាយ។ កម្មវិធីនេះក៏បានដាក់បញ្ចូលនូវសកម្មភាពបំលាស់ប្តូរសង្គមសហករណ៍មួយដែលយើងហៅថា Bayanihan។ ជាទូទៅសកម្មភាពទាំង នេះបានរួមចំណែកដល់ការអភិវឌ្ឍទីក្រុងរបស់យើង។

**៦.** **កម្មវិធីស្របគ្នា** — យុទ្ធនាការប្រឆាំងនឹងថ្នាំញៀនខុសច្បាប់ និងកម្មវិធីបរិស្ថាន ជាតម្រូវការសម្រាប់អ្នក ទទួលផលពីកម្មវិធីទាំងអស់ ក៏ដូចជាអ្នកទទួលផលដទៃទៀតនៅក្នុង SIAPP ដែរ។ យុទ្ធសាស្ត្រស្របគ្នានេះ នាំឱ្យយើងដោះបញ្ហាគ្រឿងញៀន និងសំរាមបានកាន់តែឆាប់រហ័ស តាមរយៈយុទ្ធវិធីថ្នាក់មូលដ្ឋាន និងដោយ មានការចំណាយតិចតួចបំផុត។

## តើអ្វីជាសមិទ្ធផលនៃការប្រឹងប្រែងរួមគ្នារបស់យើង?

១. កុមារដែលមានសុខភាពល្អ និងសប្បាយរីករាយនៅក្នុងភូមិ GK បន្ទាប់ពីទទួលសេវាកម្មជាមូលដ្ឋាន ចំនួន ៤ គឺសុខាភិបាល ការអប់រំ មុខរបរចិញ្ចឹមជីវិត និង ទីជម្រកស្នាក់នៅ
២. បង្កើនប្រាក់ចំណេញរបស់កសិករ
៣. បង្កើនការប្រមូលពន្ធដារ
៤. បង្កើនការប្រមូលប្រាក់ចំណូល
៥. ការផ្តល់អំណាចដល់ប្រជាពលរដ្ឋ បានបង្កើនការចូលរួមជាក្រុមតាមវិស័យ
៦. ប្រជាជនទុកចិត្តលើរដ្ឋាភិបាល ដែលធ្វើឱ្យឥរិយាលបងនៅក្នុងការបោះឆ្នោតកាន់តែប្រសើរឡើង។

## ស្លាយ : ក្របខ័ណ្ឌនាំចមូល

ការធ្វើសមាហរ័ណកម្មសង្គម និងសេដ្ឋកិច្ច ការឆ្លើយតបរួមគ្នារបស់សហគមន៍ជាមួយនឹងការដុះដាលឡើងនូវ ការអភិវឌ្ឍ ការកើនឡើងនូវផលិតភាព និងប្រាក់ចំណេញ ការកសាងសមត្ថភាពរដ្ឋបាលក្រុង ការផ្តល់ អំណាចដល់ប្រជាជន និងការធ្វើវិមជ្ឈការបទបញ្ញត្តិសវនកម្មមូលដ្ឋាន ការគ្រប់គ្រង និងការអភិវឌ្ឍ ផែនការប្រើប្រាស់ដីធ្លី ការអភិវឌ្ឍសហប្រតិបត្តិការមុខរបរចិញ្ចឹមជីវិត និងផ្តល់លទ្ធផលទាំងស្រុងដល់ជីវិត គ្រួសារ ចលនាសហការខ្លាំងក្លា ការពឹងផ្អែកលើខ្លួនឯង ចីរភាពក្នុងការបង្កើនគុណភាពជីវិតរស់នៅ សន្តិភាព និងសណ្តាប់ធ្នាប់។